# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1440

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : រៀបចំផែនការសកម្មភាពជាតិសម្រាប់វិស័យអាជីវកម្មរ៉ែមាសខ្នាតតូច និងលក្ខណៈគ្រួសារប្រទេសកម្ពុជា

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 30/10/22 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 30/09/24 |

៣. ចំណាយគម្រោងសរុប $410,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងបរិស្ថាន

| | |
|---|---|
| RESPONSIBLE UNIT | General Directorate of Environment Protection, Department of Hazardous Substances Management |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានគាំពារបរិស្ថាន នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់ |

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី៥- ការពង្រឹងប្រព័ន្ធធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះនឹងរួមចំណែកដល់ការកែលម្អគុណភាពបរិស្ថាន ដោយផ្តោតជាសំខាន់លើការកាត់បន្ថយផលប៉ះពាល់ដោយសារសារធាតុបារតដែលមានផលប៉ះពាល់អវិជ្ជមានដល់សុខភាពមនុស្ស និងបរិស្ថាន ដោយផ្តល់នូវជំនួយ បច្ចេកទេស និងហិរញ្ញវត្ថុក្នុងការរៀបចំផែនការសកម្មភាព។ បន្ថែមពីនេះទៀត ផែនការសកម្មភាពនេះផ្តោតលើផ្នែកសំខាន់ៗ ដើម្បីកាត់បន្ថយការប្រើប្រាស់បារតក្នុងវិស័យអាជីវកម្មរ៉ែមាសខ្នាតតូច លុបបំបាត់ការអនុវត្តមិនត្រឹមត្រូវក្នុងវិស័យអាជីវកម្មរ៉ែមាសខ្នាតតូច និងបង្កើនការគ្រប់គ្រងផលប៉ះពាល់បរិស្ថាន តាមរយៈជំនួយបច្ចេកទេសដល់អ្នករុករករ៉ែ កសាងសមត្ថភាពស្ថាប័នដើម្បីពង្រឹងការត្រួតពិនិត្យនិងការអនុវត្ត កែលម្អបច្ចេកទេសប្រសើរឡើង កែច្នៃនិងផ្តល់នូវវិធីសាស្រ្តដកហូតយករ៉ែមាសដោយមិនប្រើប្រាស់សារធាតុបារត។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ? មិនគាំទ្រ

១១. វិស័យ ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស

១២. ទីតាំងអនុវត្តគម្រោង ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

ព្រះវិហារ, រតនគិរី, ក្រចេះ, មណ្ឌលគិរី,

១៣. គោលបំណងរបស់គម្រោង ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

ដើម្បីជួយកម្ពុជាក្នុងការរៀបចំផែនការសកម្មភាពជាតិសម្រាប់វិស័យអាជីវកម្មរ៉ែមាសខ្នាតតូច និងលក្ខណៈគ្រួសារ លើកកម្ពស់ការយល់ដឹងអំពីអនុសញ្ញាមីណាម៉ាតា និងកសាងសមត្ថភាពស្ថាប័នសម្រាប់ការអនុវត្តផែនការសកម្មភាពជាតិនៅជំហានដំបូង។

១៤. ការពិពណ៌នាអំពីគម្រោង ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

ប្រទេសកម្ពុជាចាត់វិធានការដើម្បីកាត់បន្ថយ និងតាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីលុបបំបាត់ការប្រើប្រាស់បារត និងសមាសធាតុបារតនៅក្នុងអាជីវកម្មរ៉ែមាសខ្នាតតូច និងលក្ខណៈគ្រួសារ និងការសាយភាយ និងការបញ្ចេញនៃសារធាតុបារតទៅក្នុងបរិយាកាសពីដំណើរការនៃការជីកហូតយករ៉ែមាស តាមរយៈការរៀបចំ និងអនុវត្តផែនការសកម្មភាពជាតិដែលអនុលោមតាមឧបសម្ព័ន្ធ គ នៃ អនុសញ្ញាមីណាម៉ាតា។ ការរៀបចំផែនការសកម្មភាពជាតិមានធាតុចំនួនបី ដែលរួមមានលទ្ធផល និងសកម្មភាពដូចជា៖

១. ការគាំទ្រផ្នែកបច្ចេកទេសក្នុងការរៀបចំផែនការសកម្មភាពជាតិ

១.១. ផ្តល់ការបណ្តុះបណ្តាល និងគោលការណ៍ណែនាំក្នុងការរៀបចំផែនការកម្មភាពជាតិដែលអនុលោមតាមឧបសម្ព័ន្ធ គ នៃអនុសញ្ញាមីណាមាតា

២. ការរៀបចំផែនការសម្មភាពជាតិ

២.១ ពង្រាងផែនការសកម្មភាពជាតិស្របតាមឧបសម្ព័ន្ធ គ នៃអនុសញ្ញាមីណាម៉ាតា

៣. ការត្រួតពិនិត្យ និងវាយតម្លៃ

៣.១ ត្រួតពិនិត្យស្ថានភាពអនុវត្តគម្រោង និងសមធម៌នៃការប្រើប្រាស់នៃហិរញ្ញប្បទាន និងការទំនាក់ទំនងទៅកាន់ដៃគូអភិវឌ្ឍ

៣.២ ការត្រួតពិនិត្យពីភ្នាក់ងារឯករាជ្យ និងដាក់ចេញជាសាធារណៈ។

១៥. យុត្តិកម្មលើគម្រោង ( បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស )

ក្នុងនាមជាភាគីនៃអនុសញ្ញាមីណាម៉ាតា និងបានផ្តល់សច្ចាប័នដល់លេខាធិការដ្ឋានថាអាជីវកម្មរ៉ែមាសខ្នាតតូច និងដំណើរការផលិតកម្មស្ថិតក្នុងដែនដីរបស់ខ្លួនមានចំនួនច្រើន។ ដូច្នេះ ប្រទេសកម្ពុជាមានកាតព្វកិច្ចក្នុងការរៀបចំ និងអនុវត្តផែនការសកម្មភាពជាតិសម្រាប់វិស័យអាជីវកម្មរ៉ែមាសខ្នាតតូច និងលក្ខណៈគ្រួសារដោយអនុលោមតាមឧបសម្ព័ន្ធ គ ហើយត្រូវផ្ញើផែនការសកម្មភាពរបស់ខ្លួនទៅលេខាធិការដ្ឋានអនុសញ្ញាមីណាម៉ាតា។
បច្ចុប្បន្ន បារតឬសមាសធាតុបារតមិនទាន់បានគ្រប់គ្រងប្រកបដោយសុវត្ថិភាពបរិស្ថាននោះទេ ហើយមិនទាន់មានបទដ្ឋានគតិយុត្តផ្តោតចំបងលើការគ្រប់គ្រងសារធាតុបារត។

១៦. ផលប្រយោជន៍របស់គម្រោង ( រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង )

១. ផ្តល់គោលការណ៍ណែនាំបន្ថែមក្នុងការបង្កើតផែនការសកម្មភាពប្រកបដោយប្រសិទ្ធភាព សម្រាប់ការគ្រប់គ្រងបារតប្រកបដោយសុវត្ថិភាពបរិស្ថាន។

២.
គាំទ្រក្នុងការបង្កើតក្រុមការងារអន្តរក្រសួងក្នុងការរៀបចំផែនការសកម្មភាពជាតិសម្រាប់គ្រប់គ្រងការប្រើប្រាស់សាធាតុបារតក្នុងវិស័យអាជីវកម្មរ៉ែមាសខ្នាតតូច និងលក្ខណៈគ្រួសារ។

៣. បង្កើតក្របខណ្ឌអភិវឌ្ឍប្រកបដោយចីរភាពដែលការពារសុខភាពមនុស្ស និងបរិស្ថានដោយលុបបំបាត់ការអនុវត្តមិនត្រឹមត្រូវក្នុងវិស័យអាជីវកម្មរ៉ែមាសខ្នាតតូច និងលក្ខណៈគ្រួសារ។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **គ្មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **មិនទាន់ចាប់ផ្តើម**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌នាសង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះមិនជះឥទ្ធិពលអវិជ្ជមានណាមួយដល់សុខភាពមនុស្ស និងបរិស្ថានទេ ផ្ទុយទៅវិញគម្រោងនេះជួយលើកកម្ពស់សុខភាពមនុស្ស និងលុបបំបាត់ការកេងប្រវ័ញ្ចពលកម្មកុមារ។ នៅក្នុងផែនការសកម្មភាពជាតិនិងរួមបញ្ចូលនូវយុទ្ធសាស្ត្រក្នុងការទប់ស្កាត់ការទទួលរងឥទ្ធិពលដល់ជនងាយរងគ្រោះ ជាពិសេសកុមារ និងស្ត្រី ពីការប្រើប្រាស់សារជាតុ បារត និងការពារពីរូបភាពផ្សេងៗនៃពលកម្មកុមារក្នុងវិស័យអាជីវកម្មរ៉ែមាសខ្នាតតូច និងលក្ខណៈគ្រួសារ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះមិនប៉ះពាល់ដល់តួនាទីបុរសនិងស្ត្រីទេ ប៉ុន្តែស្ត្រីត្រូវបានលើកទឹកចិត្តឲ្យមានការចូលរួមយ៉ាងសកម្មជាមួយនឹងការអនុវត្តគម្រោងនេះ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**គម្រោងនេះត្រូវបានការជួយជ្រោមជ្រែងដោយកម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP) និងនាយកដ្ឋានគ្រប់គ្រងសារជាតុគ្រោះថ្នាក់ទៅលើផ្នែកបច្ចេកទេស ទោះយ៉ាងណាក៏ដោយ គម្រោងនេះត្រូវការជ្រើសរើសអ្នកជំនាញជាតិ និងអន្តរជាតិបន្ថែម។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**គម្រោងបាននឹងកំពុងដំណើរការពីចុងឆ្នាំ២០២២ និងគ្រោងបញ្ចប់ នៅចុងឆ្នាំ២០២៤។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

គម្រោងនេះបានទទួលហិរញ្ញប្រទានពី GEF។ ការចូលរួមពីដៃគូអភិវឌ្ឍនៅក្នុងការអនុវត្តគម្រោងរួមមាន៖

- រៀបចំបង្កើតអ្នកជំនាញ និងប្រមូលវិធីសាស្រ្តសម្រាប់រៀបចំផែនការសកម្មភាពជាតិ
- ផ្តល់នៅការគាំទ្រផ្នែកបច្ចេកទេស និងកសាងសមត្ថភាពស្ថាប័ន
- ការគ្រប់គ្រង និងផ្លាស់ប្តូរព័ត៌មាន។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 24.0 | 0.0 | 34.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 12.0 | 0.0 | 12.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 12.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 22.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 315.6 | 0.0 | 20.5 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 253.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 3.5 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 58.5 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 20.5 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 339.6 | 0.0 | 54.5 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 339.6 | 0.0 | 54.5 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Global Environment Facility | 339.6 | 0.0 | 54.5 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 339.6 | 0.0 | 54.5 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: